ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា

លេខ..ធ.ន.ជ..០២៦..០៧៤..ប្រកាសព័ត៌មាន

ថ្ងៃ ទ្រាំទិត្យ ៦កើត ខែ កត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២៦

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ការដាក់ឱ្យដំណើរការគម្រោង "បាគងទៅកាន់ពិភពលោក"

នាថ្ងៃអាទិត្យ ៦កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៦ ធនាគារជាតិនៃកម្ពុជា បានប្រកាសដាក់ឱ្យដំណើរការនូវសេវាទូទាត់ឆ្លងដែនថ្មីមួយ ដែលមានឈ្មោះថា "បាគងទៅកាន់ពិភពលោក" ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់កម្មវិធីទូទាត់បាគង អាចប្រើប្រាស់ទូរស័ព្ទដៃរបស់ខ្លួនដើម្បីទូទាត់ប្រាក់នៅបរទេសតាមរយៈមុខងារ Tap-to-Pay។ ការប្រកាសដាក់ឱ្យដំណើរការនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលវេទិកាហិរញ្ញវត្ថុអន្តរជាតិ Black Swan Summit Cambodia ដែលប្រព្រឹត្តទៅនាថ្ងៃទី១៥-១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ។

គំនិតផ្តួចផ្តើមនេះត្រូវបានអភិវឌ្ឍឡើងក្រោមក្របខណ្ឌនៃកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន Google ដោយមានធនាគារអេស៊ីលីដា ភីអិលស៊ី ជាធនាគារទំនាក់ទំនង។ អ្នកប្រើប្រាស់កម្មវិធីទូទាត់បាគងអាចបង្កើតប័ណ្ណទូទាត់និម្មិត Visa ឬ Mastercard ដោយផ្ទាល់នៅក្នុងកម្មវិធីទូទាត់បាគង រួចភ្ជាប់ប័ណ្ណនោះទៅក្នុងកាបូបឌីជីថលនៅលើទូរសព្ទរបស់ខ្លួនជាមួយ Google Pay។ បន្ទាប់មក អ្នកប្រើប្រាស់អាចប្រើប័ណ្ណនោះដើម្បីទូទាត់ថ្លៃទំនិញ និងសេវាតាមអនឡាញ ឬគ្រាន់តែយកទូរសព្ទទៅប៉ះនឹងម៉ាស៊ីនទូទាត់ប្រាក់ (POS) ដោយមិនចាំបាច់បញ្ចូលកាតនោះទេ។ តាមរយៈការដាក់ឱ្យដំណើរការគម្រោងនេះ ប្រជាជនកម្ពុជាដែលធ្វើដំណើរទៅក្រៅប្រទេសអាចទូទាត់ប្រាក់បានយ៉ាងងាយស្រួលដូចការទូទាត់ក្នុងស្រុកដែរ ដោយពុំចាំបាច់ប្រើប្រាស់ក្រដាសប្រាក់ ឬ យកប័ណ្ណទូទាត់តាមខ្លួននោះទេ។

"បាគងទៅកាន់ពិភពលោក" គឺជាការបោះជំហានថ្មីមួយទៀតសម្រាប់បាគង ដោយវិវត្តពីប្រព័ន្ធទូទាត់ក្នុងស្រុកទៅជាច្រកទូទាត់ទូទាំងសកលលោក។ កិច្ចសហការនេះ នឹងតភ្ជាប់ប្រព័ន្ធទូទាត់ជាតិរបស់កម្ពុជាទៅនឹងបណ្តាញទូទាត់ជាសកលរបស់ Visa និង Mastercard ដោយផ្តល់ជូនប្រជាជនកម្ពុជានូវមធ្យោបាយទូទាត់ប្រាក់ដែលទំនើប មានភាពងាយស្រួល សុវត្ថិភាព និងអាចទុកចិត្តបានគ្រប់ទីកន្លែងដែលពួកគេធ្វើដំណើរ។

ទំនាក់ទំនង ៖
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៩០ ១៨៩

nbccommunications@nbc.gov.kh | www.nbc.gov.kh

ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia

National Bank of Cambodia | nbccambodia

Natonal Bank of Cambodia | nationalbankofcambodia_